World Health Organization
Western Pacific Region

# កម្ពុជា

## របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៨៣

របាយការណ៍គិតត្រឹមថ្ងៃទី ២១ ខែមីនា ឆ្នាំ២០២២ ម៉ោង១០:00នាទីព្រឹក

## ស្ថានការណ៍សង្ខេបសំខាន់ៗ (ថ្ងៃទី៧ មីនា ដល់ថ្ងៃ ២០ មីនា ឆ្នាំ២០២២)

- ករណីវិជ្ជមានវីរុសកូវីដ-១៩ថ្មី បញ្ជាក់ដោយ PCR សរុបចំនួន ២.៣៧៧ និងករណីស្លាប់ថ្មីដោយសារជំងឺកូវីដ-១៩ចំនួន១០ ត្រូវបានរាយការណ៍នៅក្នុងរយៈពេល១៤ថ្ងៃចុងក្រោយនេះ។ ក្នុងចំណោម ២.១០៥ ករណីនោះ ៨៩ភាគរយជាករណីឆ្លងក្នុងសហគមន៍ ហើយ ២៧២ករណី ឬ១១ភាគរយជាករណីនាំ ចូលពីក្រៅប្រទេស។ ចំនួនករណីឆ្លងថ្មីបានធ្លាក់ចុះចំនួន ៥៩ភាគរយ និងករណីស្លាប់បានធ្លាក់ចុះចំនួន ៥៥ភាគរយ បើធៀបទៅនឹងរយៈពេល១៤ថ្ងៃកន្លងទៅ។
- ករណីសរុបទាំងអស់ចំនួន ១៣៥.០៨៥ ត្រូវបានបញ្ជាក់ថាជាករណីវិជ្ជមានវីរុសកូវីដ-១៩ និងករណីស្លាប់ចំនួន ៣.០៥២ ត្រូវបានរាយការណ៍ដោយរាជរដ្ឋាភិបាលកម្ពុជាចាប់តាំងពីថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២០មក។ ក្នុងចំណោមនោះ ១៣១.០៣៨ ករណីបានជាសះស្បើយ។
- គិតត្រឹមថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២ តេស្តសរុបចំនួន ២.៥៨៨.៥១១ ត្រូវបានធ្វើដោយប្រើម៉ាស៊ីនតេស្តមន្ទីរពិសោធន៍ (RT-PCR)។ គិតចាប់តាំងពីខែមករា ឆ្នាំ ២០២០មក បុគ្គលសរុបចំនួន ១.៨៤៨.៧២១ នាក់ បានធ្វើតេស្តរកវីរុសកូវីដ-១៩ ដោយប្រើបច្ចេកវិទ្យាធ្វើតេស្តប្រើម៉ាស៊ីននៅមន្ទីរពិសោធន៍ (Reverse-Transcriptase Polymerase Chain Reaction, RT-PCR) ដោយមានអត្រាវិជ្ជមានក្នុងកម្រិត ៥.២ ភាគរយ។
- ចំនួនករណីឆ្លងវីរុសកូវីដ-១៩ថ្មីដែលត្រូវបានរាយការណ៍ បន្តធ្លាក់ចុះជាបន្តបន្ទាប់នៅក្នុងរយៈពេលបួនសប្តាហ៍កន្លងមកនេះ។ នេះបង្ហាញពីការធ្លាក់ចុះនូវការចម្លងនៅក្នុងសហគមន៍នៅរាជធានីភ្នំពេញ។ សមត្ថភាពថែទាំសុខភាពនៅតែមានស្ថេរភាពជាមួយនឹងករណីជំងឺកូវីដ-១៩ភាគច្រើនកំពុងទទួលការថែទាំ និងសះស្បើយនៅតាមផ្ទះ។
- កាលពីថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២២ រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសលុបចោលលក្ខខណ្ឌតម្រូវឱ្យអ្នកដំណើរពីបរទេសដែលបានចាក់វ៉ាក់សាំងពេញលេញ។
- ការកែតម្រូវវិធានការសុខភាពសាធារណៈ និងសង្គមដើម្បីទប់ស្កាត់កុំឱ្យមានការចម្លងទ្រង់ទ្រាយធំ ការពង្រឹងការផ្តល់សេវាសុខភាព និងពន្លឿនការចាក់វ៉ាក់សាំងសម្រាប់ក្រុមប្រជាជនដែលងាយរងគ្រោះ នៅតែជាផ្នែកអាទិភាពដើម្បីគ្រប់គ្រងបញ្ហាកូវីដ-១៩ និងបញ្ហាផ្សេងៗនាពេលអនាគតប្រកបដោយនិរន្តរភាព។

## ការរកឃើញបានឆាប់ និងឆ្លើយតបចំគោលដៅ

- **ការតាមដានជំងឺ:**
  - អង្គការសុខភាពពិភពលោក កំពុងតែផ្តល់ការគាំទ្រដល់ក្រសួងសុខាភិបាលដើម្បីពិនិត្យនូវការប្រើតេស្តរហ័សដើម្បីធ្វើរោគវិនិច្ឆ័យ ការតាមដានជំងឺ និងការកែសម្រួលវិធានការសុខាភិបាល និងសង្គមឡើងវិញ។
  - អង្គការសុខភាពពិភពលោក កំពុងផ្តល់ការប្រឹក្សាផ្នែកបច្ចេកទេសដល់ការបង្កើតប្រព័ន្ធតាមដានលំដាប់ហ្សែនវិភាគរកប្រភេទនៃមេរោគបំប្លែងថ្មី រួមទាំងពិនិត្យឡើងវិញនូវសមត្ថភាពថែទាំសុខភាព និងប្រព័ន្ធសុខាភិបាលនាពេលបច្ចុប្បន្ន។

## វិធានការសុខភាពសាធារណៈ និងសង្គម

- កាលពីថ្ងៃទី ១៧ ខែមីនា រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសលុបចោលលក្ខខណ្ឌតម្រូវឱ្យអ្នកដំណើរពីបរទេសដែលបានចាក់វ៉ាក់សាំងពេញលេញបង្ហាញលទ្ធផលតេស្ត PCR អវិជ្ជមានក្នុងរយៈពេល៧២ម៉ោងមុនពេលមកដល់កម្ពុជា លុបចោលការតម្រូវឱ្យធ្វើតេស្តរហ័សនៅពេលមកដល់កម្ពុជា និងអនុញ្ញាតឱ្យបើកដំណើរការឡើងវិញនូវការផ្តល់ទិដ្ឋាការបេលមកដល់ (visa on arrival) សម្រាប់អ្នកដំណើរអន្តរជាតិទាំងអស់ទាំងតាមផ្លូវអាកាស ផ្លូវគោក និងផ្លូវទឹក។ រាជរដ្ឋាភិបាលលើកទឹកចិត្តដល់អ្នកដំណើរទាំងអស់ធ្វើតេស្តរហ័សដោយខ្លួនឯង បង្ហាញវិញ្ញាបនបត្របញ្ជាក់ការចាក់វ៉ាក់សាំងកូវីដ-១៩នៅពេលមកដល់កម្ពុជា ហើយអ្នកដំណើរដែលពុំបានចាក់វ៉ាក់សាំងកូវីដ-១៩ពេញលេញ ត្រូវធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ។
- កាលពីថ្ងៃទី ១៨ ខែមីនា នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាលដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក បានរៀបចំវគ្គសិក្ខាសាលាចែករំលែកបទពិសោធន៍ស្តីពីការពង្រឹងប្រព័ន្ធតាមដាន ការអនុវត្តវិធានការសុខាភិបាល និងសង្គមក្នុងបរិបទការស់នៅតាមគន្លងប្រក្រតីភាពថ្មី ដើម្បីជៀសវាងខ្សែបន្ទាត់ក្រហម និងការពារជនងាយរងគ្រោះ។ វគ្គសិក្ខាសាលានោះ បានទទួលការចូលរួមពីតំណាងក្រសួងសុខាភិបាល ក្រសួងអប់រំយុវជន និងកីឡា ក្រសួងទេសចរណ៍ ក្រសួងវប្បធម៌ និងកិច្ចការសាសនា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋបាលរាជធានីភ្នំពេញ។ ជាជំហានបន្ទាប់ទៀត សិក្ខាសាលា សម្រេចថានឹងពិនិត្យមើលលទ្ធភាពបង្កើត និងអនុវត្តឧបករណ៍រួមសម្រាប់តាមដានការអនុវត្តវិធានការសុខាភិបាល និងសង្គមជាបន្តទៀត។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សហគមន៍

- អង្គការសុខភាពពិភពលោកបានធ្វើការជាមួយនឹងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង និងមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាពក្នុងការធ្វើបច្ចុប្បន្នភាពយុទ្ធសាស្រ្តពង្រឹងការចូលរួមរបស់សហគមន៍ និងប្រាស្រ័យទាក់ទងអំពីហានិភ័យ ស្របទៅតាមការពិនិត្យឡើងវិញ និងការធ្វើផែនការនិយ័តកម្មសុខភាពអន្តរជាតិសម្រាប់ឆ្នាំ២០២២ដែលទើបតែបានធ្វើក្នុងពេលថ្មីៗនេះ។ យុទ្ធសាស្រ្តដែលត្រូវបានធ្វើបច្ចុប្បន្នភាព មានគោលដៅប្រើប្រាស់ការអនុវត្តល្អបំផុត និងមេរៀនដែលទទួលបានពីការឆ្លើយតបរយៈពេល២ឆ្នាំកន្លងមកទៅនឹងជំងឺកូវីដ-១៩ ដើម្បីពង្រឹង និងលើកកំពស់បន្ថែមទៀតនូវបទដ្ឋានសង្គមថ្មីសម្រាប់ការគ្រប់គ្រងជំងឺកូវីដ-១៩នៅកម្ពុជាប្រកបដោយនិរន្តរភាព ជាមួយនឹងគោលបំណងជូនដំណឹង និងផ្តល់អំណាចដល់បុគ្គល និងសហគមន៍ដើម្បីត្រៀមខ្លួនឱ្យរួចរាល់ និងឆ្លើយតបទៅនឹងជំងឺរាតត្បាតនាពេលអនាគត។
- អង្គការសុខភាពពិភពលោក កំពុងផ្តល់ការគាំទ្រដល់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល ដើម្បីកែសម្រួល និងផលិតវីដេអូ និងកិច្ចពិភាក្សាផ្សាយផ្ទាល់តាមអនឡាញជាមួយអ្នកជំនាញជាភាសាខ្មែរ ដើម្បីលើកកំពស់ការអនុវត្តវិធានការសុខាភិបាល និងសង្គម ហើយនិងដោះស្រាយបញ្ហាព័ត៌មានមិនពិតជុំវិញការចាក់វ៉ាក់សាំង ជាពិសេសផ្តោតលើស្ត្រីមានផ្ទៃពោះ និងសហគមន៍ពិបាកចូលទៅដល់។
- ក្រសួងសុខាភិបាល កំពុងចាប់ផ្តើមយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីជំងឺកូវីដ-១៩ថ្នាក់ជាតិ ដើម្បីអប់រំ ផ្សព្វផ្សាយ និងលើកកំពស់ការយល់ដឹងដល់ប្រជាពលរដ្ឋក្រោមប្រធានបទ "វីរុសកូវីដ-១៩ អូមីក្រុងឆ្លងលឿនខ្លាំងជាងមុន អាចបង្កឱ្យមានហានិភ័យធ្ងន់ធ្ងរដល់អ្នក និងគ្រួសារ" នៅថ្ងៃទី ២២ ខែមីនា ឆ្នាំ២០២២។

## ការចាក់វ៉ាក់សាំងកូវីដ-១៩

- រាជធានី-ខេត្តទាំង ២៥ ទទួលបានវ៉ាក់សាំងប្រភេទ Pfizer ហើយចាប់ផ្តើមចាក់វ៉ាក់សាំងដូសជម្រុញ កាលពីសប្តាហ៍មុន។
- ការពីថ្ងៃ ១៨ ខែមីនា គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ទូទាំងប្រទេស បានប្រកាសបង្កើនការប្រើប្រាស់វ៉ាក់សាំង ប្រភេទ Pfizer សម្រាប់ដូសជម្រុញទី៣ និងដូសជម្រុញទី៤សម្រាប់ប្រជាជនអាយុចាប់ពី១២ឆ្នាំឡើង និងផ្អាកប្រើវ៉ាក់សាំងប្រភេទស៊ីណូហ្វាម និងស៊ីណូវ៉ាក់សម្រាប់ដូសជម្រុញទី៣ និង៤ ដល់ក្រុមប្រជាជនអាយុចាប់ពី១២ឆ្នាំឡើង រហូតទាល់តែវ៉ាក់សាំងដែលមានកាលបរិច្ឆេទរយៈពេលខ្លីត្រូវបានប្រើអស់។
- វ៉ាក់សាំងប្រភេទ AstraZeneca (Vaxzevria) ចំនួន ៥២៣.១០០ដូសជាជំនួយពីប្រទេសហុងគ្រី ហើយនិងវ៉ាក់សាំងប្រភេទ Pfizer-BioNTech ដែលជាបំណែងចែកពីអាស៊ានចំនួន ១៣៩.២៣០ដូស បានមកដល់កម្ពុជានៅថ្ងៃទី ១៤ ខែមីនានេះ។
- វ៉ាក់សាំងប្រភេទ Pfizer-BioNTech ចំនួន ៥.៥១៥.៣៨០ដូស ពីមជ្ឈមណ្ឌលកូវ៉ាក់ជុំទី១៥ នឹងមកដល់កម្ពុជាចន្លោះពីខែមីនាដល់ខែកញ្ញា ឆ្នាំ២០២២។ ជាបំណែងចែកពីអាស៊ានចំនួន ១៣៩.២៣០ដូស បានមកដល់កម្ពុជានៅថ្ងៃទី ១៤ ខែមីនានេះ។ វ៉ាក់សាំងប្រភេទ Pfizer-BioNTech ចំនួន ២លានដូសដែលជាជំនួយរបស់សហរដ្ឋអាមេរិកតាមរយៈមជ្ឈមណ្ឌលកូវ៉ាក់ នឹងមកដល់កម្ពុជានៅខែមេសាឆ្នាំ២០២២នេះ។
- កាលពីថ្ងៃទី ១៨ ខែមីនា ប្រធានាធិបតីសាធារដ្ឋប្រជាមានិត្យចិន ស៊ី ជិនពីង បានប្រកាសផ្តល់ជំនួយជាវ៉ាក់សាំងកូវីដ-១៩ចំនួន ២០ លានដូសបន្ថែមទៀតមកដល់កម្ពុជា ដែលក្នុងនោះចំនួន៥លានដូសនឹងមកដល់កម្ពុជានៅចុងខែមីនា ឆ្នាំ២០២២នេះ។
- ការគាំទ្ររបស់អង្គការសុខភាពពិភពលោកដល់កម្មវិធីជាតិផ្តល់ថ្នាំបង្ការះ
  - កំណត់អត្តសញ្ញាណប្រជាជនដែលមិនទាន់បានចាក់វ៉ាក់សាំង និងធ្វើផែនការកម្រិតថ្នាក់ក្រោមជាតិ និងការអនុវត្តនៅតាមទីតាំងចាក់វ៉ាក់សាំង និងក្រុមការងារចុះចាក់វ៉ាក់សាំងចល័តទៅដល់សហគមន៍ដែលពិបាកចូលទៅដល់ ការប្រាស្រ័យទាក់ទង និងការចូលរួមរបស់សហគមន៍ ការតាមដាន និងត្រួតពិនិត្យនៅតាមមូលដ្ឋាន នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីចូលទៅដល់ក្រុមប្រជាជនកម្ពុជាដែលពិបាកចូលទៅដល់។
  - បានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកំពង់ឆ្នាំ និងខេត្តកំពង់ស្ពឺ ដើម្បីចាក់វ៉ាក់សាំងដល់ភូមិជុំវិញបឹងទន្លេសាប និងភូមិដាច់ស្រយាលដទៃទៀតដែលមិនទាន់បានទទួលវ៉ាក់សាំង។



**បដិសេធការទទួលខុសត្រូវ៖** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## អន្តរាគមន៍ និងការផ្តល់សេវាសុខភាព

- កិច្ចពិភាក្សាករណីគ្លីនិកតាមប្រព័ន្ធអនឡាញចំនួន៣ ត្រូវបានរៀបចំនៅខែនេះ កាលពីថ្ងៃទី ១១ ថ្ងៃទី ១៦ និងទី១៨ ខែមីនា ដោយមានការធ្វើបទបង្ហាញករណីគ្លីនិកពីមន្ទីរពេទ្យខេត្តកែប  ខេត្តកំពង់ស្ពឺ និងខេត្តបាត់ដំបង។
- ការបង្ហាត់បង្ហាញផ្ទាល់ពីរបៀបព្យាបាលដោយប្រើអុកស៊ីសែន ត្រូវបានរៀបចំក្នុងរយៈពេលពីរសប្តាហ៍មុននៅមន្ទីរពេទ្យបង្អែកស្រុកចំនួន៨ នៃខេត្តកំពង់ចាម និងនៅមន្ទីរពេទ្យបង្អែកស្រុកចំនួន៦ នៃខេត្តតាកែវ។ យ៉ាងហោចណាស់ក៏បុគ្គលិកចំនួន១០នាក់មកពីមន្ទីរពេទ្យនីមួយៗ បានចូលរួមក្នុងការបង្ហាត់បង្ហាញដោយផ្ទាល់នេះ។
- អង្គការសុខភាពពិភពលោក កំពុងសហការជាមួយនឹងក្រសួងសុខាភិបាល ដើម្បីពង្រឹងការព្យាបាល ថែទាំអ្នកជំងឺកូវីដ-១៩នៅតាមផ្ទះ និងតាមដានជំងឺនៅតាមមន្ទីរពេទ្យដើម្បីបញ្ចៀសបញ្ហាលើសពីសមត្ថភាពថែទាំសុខភាពរួមទាំងការពិនិត្យឯកសារប្រាស្រ័យទាក់ទង និងគោលការណែនាំឡើងវិញ។ ការស្ទង់មតិមួយស្តីពីការថែទាំ និងព្យាបាលនៅតាមផ្ទះ ត្រូវបានរៀបចំនៅខេត្តសៀមរាប ខេត្តកំពង់ចាម និងខេត្តព្រៃវែង ហើយនឹងត្រូវរៀបចំនៅក្នុងខេត្តកណ្តាលនៅសប្តាហ៍នេះ និងនៅរាជធានីភ្នំពេញនៅសប្តាហ៍ក្រោយ។

## អេពីដេមីសាស្ត្រ

### ក្រាហ្វិកទី១. ខ្សែកោងអេពីដេមិកនៃករណីជំងឺកូវីដ-១៩ បញ្ជាក់ដោយមន្ទីរពិសោធន៍ បែងចែកតាមកាលបរិច្ឆេទនៃរបាយការណ៍ឆ្នាំ២០២១-២០២២*




*ចាប់ពីថ្ងៃ ៣០ ខែកញ្ញាឆ្នាំ២០២១មក មានតែលទ្ធផលតេស្តវីរុសកូវីដ-១៩ បញ្ជាក់ដោយ PCR ប៉ុណ្ណោះដែលត្រូវបានរាយការណ៍ជាចំនួនករណីឆ្លងផ្លូវការ



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩  ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## តារាងទី១. តារាងសង្ខេបអំពីស្ថានភាពកូវីដ-១៩

| | | | | |
|---|---|---|---|---|
| **បច្ចុប្បន្នភាពអេពីដេមីសាស្ត្រអំពីកូវីដ-១៩** | ចំនួនតេស្ត | ករណីឈឺ | ករណីស្លាប់ | |
| | 25,281<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចក្នុងពេល១៤ថ្ងៃចុងក្រោយ | 2,377<br>ករណីវិជ្ជមានថ្មីក្នុងពេល១៤ថ្ងៃចុងក្រោយ | 10<br>ករណីស្លាប់ក្នុងពេល១៤ថ្ងៃចុងក្រោយ | 272<br>ករណីនាំចូលក្នុងពេល១៤ថ្ងៃចុងក្រោយ |
| | 2,588,511<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចសរុប | 135,085<br>ករណីសរុប | 3,052<br>ករណីស្លាប់សរុប | |
| **ការផ្តល់សេវាសុខភាពអំពីកូវីដ-១៩** | 79<br>ចំនួនមន្ទីរពេទ្យដែលទទួលព្យាបាលអ្នកជំងឺកូវីដ-១៩ | 145<br>ចំនួនមណ្ឌលព្យាបាលអ្នកជំងឺកូវីដ-១៩ | 1,626<br>ចំនួនគ្រែអ្នកជំងឺធ្ងន់ដែលមាននៅមន្ទីរពេទ្យ និង មណ្ឌលព្យាបាល | |

## តារាងទី២. ការវាយតម្លៃ[1]អំពីដំណាក់កាលចម្លងតាមខេត្តនីមួយៗ

| ដំណាក់កាលចម្លង | ខេត្ត |
|---|---|
| ដំណាក់កាលចម្លងទី៣: ការឆ្លងក្នុងសហគមន៍ទ្រង់ទ្រាយធំ | រាជធានីភ្នំពេញ |
| ដំណាក់កាលចម្លងទី២: ការឆ្លងក្នុងសហគមន៍តាមតំបន់ | ខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តព្រះវិហារ ខេត្តស្វាយរៀង ខេត្តត្បូងឃ្មុំ ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ខេត្តកោះកុង ខេត្តកែប ខេត្តក្រចេះ និងខេត្តប៉ៃលិន |
| ដំណាក់កាលចម្លងទី១: ករណីនាំចូល | ខេត្តពោធិសាត់ ខេត្តមណ្ឌលគិរី និងខេត្តរតនៈគិរី |

[1] តំណាក់កាលចម្លងសម្រាប់ការចាត់ថ្នាក់កម្រិតថ្នាក់ក្រោមជាតិដោយអង្គការសុខភាពពិភពលោកប្រចាំតំបន់ប៉ាស៊ីហ្វិកខាងលិច



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**តារាងទី៣. យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩តាមក្រុមគោលដៅ (បុគ្គលិកសុខាភិបាល មនុស្សចាស់ មនុស្សពេញវ័យ និងកុមារ)**

| | បុគ្គលិកសុខាភិបាល | មនុស្សពេញវ័យ | | យុវវ័យ និងកុមារ | | | |
|---|---|---|---|---|---|---|---|
| | | អាយុចាប់ពី ៦០ឆ្នាំ | អាយុចាប់ពី ១៨ឆ្នាំ | អាយុ៣-៤ ឆ្នាំ | អាយុ៥ឆ្នាំ | អាយុពី៦ឆ្នាំ ដល់ក្រោម ១២ឆ្នាំ | អាយុចាប់១២ ឆ្នាំដល់ក្រោម ១៨ឆ្នាំ |
| | (N=43,646) | (N=1,378,688) | (N=10,000,000) | (N=610,730) | N=304,317) | (N=1,897,382) | (N=1,827,348) |
| ចាប់ផ្ដើម (2021) | 10 កុម្ភៈ 2021 | 10 កុម្ភៈ 2021 | 10 កុម្ភៈ:2021 | 22 កុម្ភៈ 2022 | 1 វិច្ឆិកា 2021 | 17 កញ្ញា 2021 | 1 សីហា 2021 |
| ដូសទី១ | 43,646 (100%) | 1,406,508 (102.0%) | 10,258,409 (102.6%) | 280,183 (45.9%) | 370,881 (121.9%) | 2,040,619 (107.5%) | 1,828,588 (100.1%) |
| ដូសទី២ | 43,646 (100%) | 1,389,421 (100.8%) | 9,909,359 (99.1%) | N/A | 268,156 (88.1%) | 1,956,667 (103.1%) | 1,760,884 (96.4%) |
| ដូសទី៣ | 43,646 (100%) | 855,075 (62.0%) | 5,814,377 (58.1%) | N/A | | 773,395 (40.8%) | 1,173,505 (64.2%) |
| ដូសទី៤ | 1,113,738 (11.1%) | | | | | N/A | N/A |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**តារាងទី៤. អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស តាមប្រភេទវ៉ាក់សាំងកូវីដ-១៩**

| ប្រភេទវ៉ាក់សាំងកូវីដ-១៩ | Sinovac | Sinopharm | AstraZeneca (Covishield) | Janssen (Ad26.COV2-S) | AstraZeneca (Vaxzevria) | Moderna (Spikevax) | Pfizer BioNTech (Comirnary) | សរុប |
|---|---|---|---|---|---|---|---|---|
| ចំនួនករណី | 101 | 79 | 29 | 4 | 1 | 3 | 0 | **217** |
| ចំនួនដូសសរុបបានចាក់ | 23,784,464 | 7,457,401 | 323,344 | 1,053,151 | 2,640,564 | 345,918 | 890,768 | **37,548,761** |
| អត្រានៃហេតុការណ៍ក្នុងចំណោម ១០០.០០០ដូស | 0.43 | 1.06 | 8.97 | 0.38 | 0.08 | 0.87 | 0 | **0.60** |

## ឯកសារយើង និងតំណរភ្ជាប់ដែលពាក់ព័ន្ធ

- គេហទំព័រក្រសួងសុខាភិបាល: គេហទំព័រផ្លូវការរបស់ក្រសួងសុខាភិបាល
- របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ដោយក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក: របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់ប្រទេសកម្ពុជា។
- របាយការណ៍ស្តីពីស្ថានភាពថ្នាក់តំបន់:របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់អង្គការសុខភាពពិភពលោកតំបន់ប៉ាស៊ីហ្វិកខាងលិច។
- របាយការណ៍ស្តីពីស្ថានភាពថ្នាក់សាកល: របាយការណ៍បច្ចុប្បន្នភាពស្តីពីកូវីដ-១៩ផ្នែកប្រតិបត្តិការ និងអេពីដេមីសាស្រ្តរបស់អង្គការសុខភាពពិភពលោកថ្នាក់សាកល។
- គោលការណែនាំរបស់អង្គការសុខភាពពិភពលោក: គោលការណែនាំសម្រាប់ប្រទេស និងបច្ចេកទេសអំពីកូវីដ-១៩ចុងក្រោយបំផុតរបស់អង្គការសុខភាពពិភពលោក។
- ក្ដារព័ត៌មានឌីជីថលស្តីពីកូវីដ-១៩របស់អង្គការសុខភាពពិភពលោក: ទិន្នន័យកូវីដ-១៩កម្រិតតំបន់ និងពិភពលោកចុងក្រោយបំផុត។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។